គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ............................/គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី........ ខែ............ ឆ្នាំ២០១....

# សេចក្តីប្រកាសព័ត៌មាន
## សិក្ខាសាលាជាតិស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ នៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)

លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប) សូមជូនដំណឹងដល់សាធារណជន និងបណ្តាញសារព័ត៌មានទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាឱ្យបានជ្រាបថា គ.ជ.អ.ប នឹងរៀបចំសិក្ខាសាលាជាតិ ស្តីពីការរៀបចំផែនការសកម្មភាព និងថវិកាឆ្នាំ២០១៧ របស់ខ្លួនចាប់ពីថ្ងៃទី២៤-២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅសាលប្រជុំក្រសួងមហាផ្ទៃ (អគារS)។

សិក្ខាសាលានេះនឹងប្រារព្ធពិធីបើកនៅវេលាម៉ោង ០៨:០០ព្រឹក ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រោមអធិបតីភាព **ឯកឧត្តមទេសរដ្ឋមន្ត្រី អូន ព័ន្ធមុនីរ័ត្ន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** និងពិធីបិទសិក្ខាសាលានៅវេលាម៉ោង ១៥:០០រសៀល ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៦ ក្រោមអធិបតីរបស់ **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប**។

គោលបំណងនៃសិក្ខាសាលា គឺដើម្បីពិភាក្សាអំពីលទ្ធផលរំពឹងទុកសម្រាប់ផែនការសកម្មភាព និងថវិកា ឆ្នាំ២០១៧ និងបញ្ហាប្រឈមនានាដែលបានអនុវត្តក្នុងឆ្នាំ២០១៦។

សិក្ខាសាលាជាតិដ៏មានសារៈសំខាន់នេះ នឹងមានការចូលរួមពីតំណាងក្រសួង ស្ថាប័នថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសង្គមស៊ីវិលមានចំនួនសរុបប្រមាណជាង៥០០នាក់។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន និងសូមអញ្ជើញអ្នកសារព័ត៌មានចូលរួមយកព័ត៌មាន។

*សូមទំនាក់ទំនងលេខាធិការដ្ឋាន គ.ជ.អ.ប ជាមុនតាមរយៈ:*

*លេខទូរស័ព្ទ: 077 785 445 / 078 575 775*

*Email: tharith@ncdd.gov.kh*

*Website: www.ncdd.gov.kh*